**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

វិទ្យាស្ថានជាតិសុខភាពសាធារណៈ
លេខ..........១៦៣៤...វជសស

ថ្ងៃសុក្រ.....៣កើត.....ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស២៥៦៨.....
ភ្នំពេញ ថ្ងៃទី.....០៦.......ខែ...កញ្ញា....ឆ្នាំ២០២៤....

# សេចក្តីជូនដំណឹង
# ការបើកវគ្គបង់ថ្លៃសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
# នៅសាលាសុខភាពសាធារណៈ នៃវិទ្យាស្ថានជាតិសុខភាពសាធារណៈ

**យោង៖** លិខិតលេខ ០៤០០ អបស.អធម ចុះថ្ងៃអង្គារ ៣រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការអនុញ្ញាតឱ្យបើកវគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅសាលាសុខភាពសាធារណៈ។

សាលាសុខភាពសាធារណៈ នៃវិទ្យាស្ថានជាតិសុខភាពសាធារណៈ សូមជូនដំណឹងដល់បេក្ខជន-បេក្ខនារីឲ្យបានជ្រាបថា សាលាចាប់ផ្តើមទទួលពាក្យសុំចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សម្រាប់ឆ្នាំសិក្សា ២០២៤-២០២៦។

កម្មវិធីបណ្តុះបណ្តាលនេះ ប្រព្រឹត្តទៅជារៀងរាល់ ថ្ងៃសៅរ៍ និង ថ្ងៃអាទិត្យ និងធ្វើឡើងជាភាសាខ្មែរ និងជាភាសាអង់គ្លេស។ នៅពេលបញ្ចប់ការសិក្សា និស្សិតអាចសរសេរនិក្ខេបបទជាភាសាខ្មែរ ឬជាភាសាអង់គ្លេស ទៅតាមសមត្ថភាពភាសារបស់និស្សិត។

## ក. ចំនួនបេក្ខជន-បេក្ខនារី ដែលត្រូវជ្រើសរើស នៅតាមមុខជំនាញបណ្តុះបណ្តាលនៅសាលាសុខភាពសាធារណៈ៖

| មុខជំនាញ | ចំនួន |
|---|---|
| ១-បរិញ្ញាបត្រជាន់ខ្ពស់សុខភាពសាធារណៈ | ៥០ រូប |
| • ផ្នែកអភិវឌ្ឍន៍ប្រព័ន្ធសុខាភិបាល ជំនាន់ទី១៨ (Master of Public Health in Health System Development, Batch 18) | |
| ២- បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រ (Master of Science)៖ | |
| • ផ្នែកអេពីដេមីសាស្ត្រ ជំនាន់ទី១៤ (MSc in Epidemiology, Batch 14) | ៣០ រូប |
| • ផ្នែកអាហារូបត្ថម្ភ ជំនាន់ទី១៣ (MSc in Nutrition, Batch 13) | ៣០ រូប |
| ៣- បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងរដ្ឋបាលមន្ទីរពេទ្យ ជំនាន់ទី១១ (Master of Hospital Administration, Batch 11) | ៤០ រូប |

៤- បរិញ្ញាបត្រជាន់ខ្ពស់សុខភាព និងអភិវឌ្ឍន៍សហគមន៍ ជំនាន់ទី៦ ២០ រូប
(Master of Health and Community Development, Batch 6)

## ខ. តម្រូវការឯកសារក្នុងការទទួលពាក្យសុំចូលរៀន៖

- ពាក្យសុំចូលរៀន (សូមបំពេញអនឡាញ និងទាញយកឯកសារចេញ) ០១ ច្បាប់
- សញ្ញាបត្រខ្ពស់បំផុត (ច្បាប់ថតចម្លងផ្លូវការ) ០២ ច្បាប់
- ព្រឹត្តប័ត្រពិន្ទុនៃសញ្ញាបត្រខ្ពស់បំផុត ០១ ច្បាប់
- បញ្ជីឈ្មោះប្រឡងចេញថ្នាក់ជាតិ (ច្បាប់ថតចម្លង) ០១ ច្បាប់
- ជីវប្រវត្តិផ្ទាល់ខ្លួន និងការងារមានបិទរូបថតថ្មី (CV) ជាភាសាអង់គ្លេស ០១ ច្បាប់
- រូបថតដែលទើបថតថ្មី (៦ខែ ផ្ទៃពណ៌ស) ទំហំ ៤x៦ ស.ម ០២ ច្បាប់
- វិញ្ញាបនបត្រភាសាអង់គ្លេសប្រភេទ TOEFL or IELTS ឬផ្សេងពីនេះ ០១ ច្បាប់
- លិខិតបញ្ជាក់ ឬគាំទ្រពីកន្លែងការងារ ឬសាលា (បើមាន) ០១ ច្បាប់
- លិខិតបង្ហាញពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួន (personal statement) ទាក់ទងនឹងការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដែលបានជ្រើសរើសនេះ (សរសេរជាភាសាខ្មែរ ឬភាសាអង់គ្លេស) យ៉ាងច្រើនមួយទំព័រ ០១ សន្លឹក

## គ. សញ្ញាបត្រដែលអាចដាក់ពាក្យសុំចូលរៀន៖

- **សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សុខភាពសាធារណៈ៖**
  និស្សិតត្រូវមានសញ្ញាបត្រ បរិញ្ញាបត្រវិទ្យាសាស្ត្រវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តវេទនសាស្ត្រ គិលានុបដ្ឋាក ឆ្មបគិលានុបដ្ឋាក-ឆ្មប (៣+១) ឬបរិញ្ញាបត្រទាក់ទងវិទ្យាសាស្ត្រសុខាភិបាល ឬសញ្ញាបត្រសមមូល។
- **សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រ៖**
  និស្សិតត្រូវមានសញ្ញាបត្របរិញ្ញាបត្រ វិទ្យាសាស្ត្រ ឬបរិញ្ញាបត្រវិទ្យាសាស្ត្រវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តវេទនសាស្ត្រ គិលានុ-បដ្ឋាក ឆ្មប គិលានុបដ្ឋាក-ឆ្មប (៣+១) ឬបរិញ្ញាបត្រទាក់ទងវិទ្យាសាស្ត្រសុខាភិបាល ឬសញ្ញាបត្រសមមូល។
- **សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងរដ្ឋបាលមន្ទីរពេទ្យ៖**
  និស្សិតត្រូវមានបរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ក្នុងជំនាញណាមួយ។
- **សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សុខភាពនិងអភិវឌ្ឍន៍សហគមន៍៖**
  និស្សិតត្រូវមានសញ្ញាបត្របរិញ្ញាបត្រក្នុងជំនាញណាមួយ។

## ឃ. ការទទួលពាក្យ៖

- កាលបរិច្ឆេទទទួលពាក្យ គឺចាប់ពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៤។
- ពេលវេលាទទួលពាក្យ នៅពេលព្រឹក ពីម៉ោង ០៨:០០ នាទី ដល់ម៉ោង ១១:០០ នាទី និងពេលរសៀល ពីម៉ោង ១៤:០០ នាទី ដល់ម៉ោង ១៧:០០ នាទី។
- ទីកន្លែងទទួលពាក្យ គឺអាគារបាយ័ន (ជាន់ទី១) នៃវិទ្យាស្ថានជាតិសុខភាពសាធារណៈ។
- កាលបរិច្ឆេទចាប់ផ្តើមវគ្គសិក្សា គឺនៅថ្ងៃសៅរ៍ ៨រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៤។

## ង. ព័ត៌មានទំនាក់ទំនង៖

- កញ្ញា ភូ សុជាតា អ្នកសម្របសម្រួលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងរដ្ឋបាលមន្ទីរពេទ្យ និងអ្នកទទួលពាក្យសុំចូលរៀន
  លេខទូរស័ព្ទ៖ (៨៥៥) ១៧ ៣០៣ ០០៥ / អ៊ីម៉ែល៖ sph_admin@niph.org.kh
- លោកស្រី ម៉ា សុវី អ្នកសម្របសម្រួលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សុខភាព និងអភិវឌ្ឍន៍សហគមន៍
  លេខទូរស័ព្ទ៖ (៨៥៥) ៨៩ ៧៧៩ ៨៧៨ / អ៊ីម៉ែល៖ sokvyma14@gmail.com
- លោកស្រី ឡុង សិរីរស្មី អ្នកសម្របសម្រួលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សុខភាពសាធារណៈ
  លេខទូរស័ព្ទ៖ (៨៥៥) ១២ ២៦៦ ០១៥ / អ៊ីម៉ែល៖ lsereyraksmey@niph.org.kh
- លោក ហៃ វណ្ណនិត អ្នកសម្របសម្រួលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រ
  លេខទូរស័ព្ទ៖ (៨៥៥) ៧៧ ៣៣៣ ៧៩៤ / អ៊ីម៉ែល៖ hayvannith@niph.org.kh
- **អាសយដ្ឋាន៖** ឡូត៍លេខ៨០ មហាវិថីសម្តេច ប៉ែន នុត (២៨៩) សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក
- សម្រាប់ព័ត៌មានសិក្សានានា សូមចូលមើលទៅក្នុងគេហទំព័រផ្លូវការរបស់សាលា
- សម្រាប់ពាក្យសុំចូលរៀន សូមបំពេញតាមអនឡាញដែលសាលានឹងចេញជូននៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ខាងមុខនេះ និងសូមទាញយកពាក្យដែលបានបំពេញត្រឹមត្រូវភ្ជាប់ជាមួយឯកសារស្នើសុំ (ក្នុងទំព័រទី២) មកប្រគល់ជូនសាលា។

SPH-NIPH Website

SPH-NIPH Facebook

SPH-NIPH MAP

នាយកវិទ្យាស្ថាន

Sopheak

សាស្ត្រាចារ្យ ហេង_សុភាព